សុខភាព និងជីវិត
កាន់តែប្រសើរ



# សុវត្ថិភាពកូនអ្នក ជាកត្តាចម្បង

## អត្ថប្រយោជន៍ការពារគ្រោះថ្នាក់ចៃដន្យសម្រាប់កូន

កូនតូចៗ ជាមោទនភាព និងជាក្តីរីករាយសម្រាប់អ្នក – អ្នកនឹងធ្វើគ្រប់យ៉ាងដើម្បីធានាសុវត្ថិភាព និងការពារកូនជាទីស្រលាញ់របស់អ្នក។ ទោះជាយ៉ាងណា អ្នកអាចប្រឈមនឹងបញ្ហា ប្រសិនបើមានគ្រោះថ្នាក់ចៃដន្យណាមួយដែលអាចកើតឡើងជាជាយថាហេតុបានគ្រប់ពេលវេលា មកលើកូនអ្នក ហើយអ្នកពិតជាត្រូវការជំនួយជាចាំបាច់ផ្នែកហិរញ្ញវត្ថុក្នុងកាលៈទេសៈនេះ។

ផលិតផលធានារ៉ាប់រងបន្ថែម “អត្ថប្រយោជន៍ការពារគ្រោះថ្នាក់ចៃដន្យសម្រាប់កូន” គឺជាគម្រោងធានារ៉ាប់រងបុគ្គលដែលផ្តល់ការការពារលើគ្រោះថ្នាក់ចៃដន្យសម្រាប់កុមារ ក្នុងករណីគ្រោះថ្នាក់ចៃដន្យបណ្តាលឱ្យទទួលមរណភាព ពិការភាព និងការរលាក លើកុមារដែលមានអាយុចាប់ពី30 ថ្ងៃឡើងទៅ។

## អត្ថប្រយោជន៍សំខាន់ពិសេសៗ

# តើគម្រោងនេះអាចជួយឱ្យកូនរបស់អ្នកទទួលបានការការពារយ៉ាងពេញលេញដូចម្តេច?

គម្រោងធានារ៉ាប់រងដំបូងគេដែលផ្តល់ការការពារលើពិការភាពដោយផ្នែក និងជាអចិន្ត្រៃយ៍ ឬរលាកកម្រិតទីពីរ សម្រាប់កុមារ

100% នៃទឹកប្រាក់ធានារ៉ាប់រងនឹងផ្តល់ជូន ក្នុងករណីមរណភាពដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ
(អត្ថប្រយោជន៍លើមរណភាពដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ*)

100% នៃទឹកប្រាក់ធានារ៉ាប់រងនឹងផ្តល់ជូន ក្នុងករណីពិការភាពទាំងស្រុង ឬរលាកកម្រិតទីបី ដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ
(អត្ថប្រយោជន៍លើពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ឬរលាកកម្រិតទីបី ដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ*)

50% នៃទឹកប្រាក់ធានារ៉ាប់រងនឹងផ្តល់ជូន ក្នុងករណីពិការភាពដោយផ្នែក ឬរលាកកម្រិតទីពីរ ដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ
(អត្ថប្រយោជន៍លើពិការភាពដោយផ្នែកនិងជាអចិន្ត្រៃយ៍ ឬរលាកកម្រិតទីពីរ ដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ)



**សម្គាល់៖** *ចំនួនទឹកប្រាក់អតិបរមាដែលត្រូវផ្តល់សំណងសម្រាប់ផលិតផលធានារ៉ាប់រងនេះ មិនត្រូវលើសពី100%នៃទឹកប្រាក់ធានារ៉ាប់រងនៃផលិតផលធានារ៉ាប់រងបន្ថែម។ ក្រុមហ៊ុន AIA នឹងផ្តល់ជូនទឹកប្រាក់សំណង បន្ទាប់ពីដកចេញនូវទឹកប្រាក់សំណងដែលបានបង់ជូនសម្រាប់អត្ថប្រយោជន៍លើពិការភាពដោយផ្នែក និងជាអចិន្ត្រៃយ៍ ឬរលាកកម្រិតទីពីរ ដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ (ប្រសិនបើមាន)។

## ឧទាហរណ៍៖

# ធានាទំនុកចិត្ត និងផ្តល់ការការពារសម្រាប់កូនតូចៗរបស់អ្នកនៅសាលារៀន

**លោកស្រី បុប្ផា** អាយុ 28 ឆ្នាំ ជាម្តាយដែលមានកូនប្រុសមួយអាយុ 3 ឆ្នាំ ឈ្មោះ **សិទ្ធីស័ក្តិ**។ លោកស្រីបានរៀបចំគម្រោងការការពារកូនរបស់គាត់ ជាមួយផលិតផលធានារ៉ាប់រងមូលដ្ឋាន “**AIA ការពារកូន**” ។ នេះជាឆ្នាំទីមួយដែល **សិទ្ធីស័ក្តិ** ចូលរៀនដំបូង សុវត្ថិភាពកូនរបស់គាត់ជាក្តីកង្វល់ និងជារឿងដ៏សំខាន់ចំពោះគាត់ ដូច្នេះគាត់បានសម្រេចចិត្តទទួលយកការការពារបន្ថែមពីផលិតផលធានារ៉ាប់រងបន្ថែម **“អត្ថប្រយោជន៍ការពារគ្រោះថ្នាក់ចៃដន្យសម្រាប់កូន”** ដើម្បីធានាថាកូនរបស់គាត់ទទួលបានការការពារយ៉ាងពេញលេញជាមួយនឹងចំនួនទឹកប្រាក់ធានារ៉ាប់រងបន្ថែមចំនួន US$10,000 ។ លោកស្រីជ្រើសរើសរយៈពេលនៃការធានារ៉ាប់រងចំនួន 19 ឆ្នាំជាមួយនឹងការទូទាត់បុព្វលាភធានារ៉ាប់រងរយៈពេល 15 ឆ្នាំ និងការបង់បុព្វលាភធានារ៉ាប់រងប្រចាំឆ្នាំ **US$15.10** (ទឹកប្រាក់បុព្វលាភធានារ៉ាប់រងនេះសម្រាប់តែផលិតផលធានារ៉ាប់រងបន្ថែមប៉ុណ្ណោះ)។

## អត្ថប្រយោជន៍ផ្តល់ជូនក្រុមគ្រួសារលោកស្រី បុប្ផា

ក្នុងករណីមានរឿងអកុសលណាមួយបានកើតឡើងចំពោះ សិទ្ធីស័ក្តិ ដោយសារគ្រោះថ្នាក់ចៃដន្យណាមួយក្នុងកំឡុងពេលទទួលការការពារ គ្រួសាររបស់លោកស្រី បុប្ផា នឹងទទួលបានការផ្តល់សំណងទៅតាមព្រឹត្តិការណ៍ដែលកើតឡើង ដូចខាងក្រោម៖

| ប្រភេទអត្ថប្រយោជន៍ធានារ៉ាប់រង | អត្ថប្រយោជន៍ផ្តល់ជូន |
|---|---|
| • អត្ថប្រយោជន៍លើមរណភាពដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ | **US$10,000*** |
| • អត្ថប្រយោជន៍លើពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ឬរលាកកម្រិតទីបី ដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ | **US$10,000*** |
| • អត្ថប្រយោជន៍លើពិការភាពដោយផ្នែក និងជាអចិន្ត្រៃយ៍ ឬរលាកកម្រិតទីពីរ ដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ | **US$5,000** |

**សំគាល់៖** *ចំនួនទឹកប្រាក់ធានារ៉ាប់រងនេះនឹងត្រូវបានផ្តល់ជូន ក្នុងករណីមិនមានការទាមទារសំណងលើអត្ថប្រយោជន៍លើពិការភាពដោយផ្នែក និងជាអចិន្ត្រៃយ៍ ឬរលាកកម្រិតទីពីរ។

## ព័ត៌មានសង្ខេបស្ដីពីផលិតផល

- **អាយុចុះឈ្មោះដំបូង**
  30 ថ្ងៃ -17 ឆ្នាំ
- **អាយុផុតកំណត់**
  22 ឆ្នាំ
- **រយៈពេលនៃការធានារ៉ាប់រង**
  ដូចគ្នាទៅនឹងរយៈពេលនៃការធានារ៉ាប់រងសម្រាប់ផលិតផលធានារ៉ាប់រងមូលដ្ឋានដែលភ្ជាប់ជាមួយ ដោយអនុលោមតាមអាយុរបស់អ្នកត្រូវបានធានារ៉ាប់រង អតិបរមាត្រឹម អាយុ 22 ឆ្នាំ។
- **រយៈពេលនៃការបង់បុព្វធានារ៉ាប់រង**
  ដូចគ្នាទៅនឹងរយៈពេលនៃការធានារ៉ាប់រងសម្រាប់ផលិតផលធានារ៉ាប់រងបន្ថែមនេះ ឬអនុលោមតាមរយៈពេលនៃការធានារ៉ាប់រងសម្រាប់ផលិតផលធានារ៉ាប់រងមូលដ្ឋានដែលភ្ជាប់ជាមួយ។

## ការទាមទារសំណង

ប្រសិនសិនបើអ្នក ចង់ធ្វើការទាមទារសំណង អ្នកត្រូវបំពេញទម្រង់បែបបទទាមទារសំណង និងផ្ដល់ភស្តុតាង ក្នុងកំឡុងពេល 90 ថ្ងៃនៃថ្ងៃប្រតិទិន ពីការកើតឡើងនៃព្រឹត្តិការណ៍ដែលត្រូវបានធានារ៉ាប់រង។ អ្នកអាចទាញយកទម្រង់បែបបទទាមទារសំណង ពីគេហទំព័ររបស់យើង គឺ **aia.com.kh** ឬ ពីទីប្រឹក្សាផែនការជីវិត AIA។

រាល់ឯកសារ និងភស្តុតាងចាំបាច់ដែលត្រូវដាក់ភ្ជាប់ជាមួយនឹងទម្រង់បែបបទទាមទារសំណងមកកាន់ក្រុមហ៊ុន AIA មានដូចជា លិខិតមរណភាព លិខិតបញ្ជាក់ពីពិការភាព (ដោយផ្នែក ឬទាំងស្រុង និងជាអចិន្ត្រៃយ៍) វិញ្ញាបនបត្រវេជ្ជសាស្ត្រ ឬរបាយការណ៍ចេញពីមន្ទីរពេទ្យបញ្ជាក់ពីការរលាក (បញ្ជាក់ពីកម្រិតនៃការរលាក) ជាដើម និងឯកសារវេជ្ជសាស្ត្រផ្សេងទៀត។ រាល់ឯកសារវេជ្ជសាស្ត្រទាំងអស់ ត្រូវតែចេញដោយ និងទទួលស្គាល់ពីមន្ទីរវេជ្ជសាស្ត្រដែលមានអាជ្ញាបណ្ណស្របច្បាប់លើសេវាព្យាបាលវេជ្ជសាស្ត្រនៅក្នុងប្រទេស។

អ្នកទាមទារសំណងអាចស្នើសុំសំណង ប្រសិនបើព្រឹត្តិការណ៍អកុសលណាមួយ កើតឡើងក្នុងកំឡុងពេលបណ្ណសន្យារ៉ាប់រងកំពុងមានសុពលភាព។

**ការទទួលយកសំណើធានារ៉ាប់រង**
សូមទាក់ទង ទីប្រឹក្សាផែនការជីវិត AIA ឬសេវាបម្រើអតិថិជន AIA Client Care

AIA CAMBODIA
TELEGRAM CHANNEL
SCAN TO REGISTER

**086 999 242 / 023 999 242,**
**kh.care@aia.com**
**aia.com.kh**
AIA Cambodia Telegram Channel

## ករណីមិនធានា

រាល់របួសស្នាម ដែលកើតឡើងដោយផ្ទាល់ ឬដោយប្រយោល របួសទាំងស្រុង ឬផ្នែកណាមួយ ពីករណីណាមួយខាងក្រោមនេះ នឹងមិនត្រូវចាត់ចូលជារបួសស្នាមដោយគ្រោះថ្នាក់៖

1. ការបង្កឱ្យកើតអំពើហិង្សាលើរាងកាយ ឬឃាតកម្ម ឬ
2. កុបកម្ម និងចលាចល ឬភេរវកម្ម ឬ
3. ការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ ដោយម្ចាស់បណ្ណសន្យារ៉ាប់រង ឬដោយអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ឬ
4. ការធ្វើអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាត ឬធ្វើឱ្យរបួសខ្លួនឯងណាមួយទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ ឬ
5. សង្គ្រាមដែលបានប្រកាស ឬមិនបានប្រកាស ឬបដិវត្តន៍ ឬ
6. ការចូលបម្រើក្នុងជួរកងទ័ព ក្នុងកំឡុងពេលមានប្រកាស ឬគ្មានប្រកាសសង្គ្រាមក្ដី ឬក្រោមបញ្ជាប្រតិបត្តិការសង្គ្រាម ឬការស្តារសណ្តាប់ធ្នាប់សាធារណៈ ឬ
7. ឧបទ្ទវហេតុដែលកើតឡើងខណៈពេលដែល ឬដោយសារអ្នកត្រូវបានធានារ៉ាប់រងស្ថិតក្រោមឥទ្ធិពលជាតិស្រវឹង ឱសថដែលមិនបានចេញដោយវេជ្ជបញ្ជា ឬគ្រឿងញៀនខុសច្បាប់ផ្សេងៗ ឬ
8. ការចូលរួមក្នុងការធ្វើដំណើរតាមផ្លូវអាកាស លើកលែងតែអ្នកត្រូវបានធានារ៉ាប់រងជាអ្នកដំណើរធម្មតាក្នុងយន្តហោះពាណិជ្ជកម្មដែលបានចុះបញ្ជីការត្រឹមត្រូវ ឬ
9. ពិការភាពដែលបណ្តាលមកពីបញ្ហាផ្លូវកាយ ឬផ្លូវចិត្តដែលកើតមានមុនកាលបរិច្ឆេទដែលបណ្ណសន្យារ៉ាប់រងមានសុពលភាព ហើយដែលមិនបានបង្ហាញក្នុងពាក្យស្នើសុំ ឬរបាយការណ៍សុខភាព ឬ
10. ការចូលរួមក្នុងកីឡាអាជីព ឬសកម្មភាពដែលមានគ្រោះថ្នាក់ដូចជា ការហក់លោតពីទីអាកាសខ្ពស់ (skydiving) ការលោតឆ័ត្រយោង (parachuting) ការលោតពីទីខ្ពស់ដោយប្រើខ្សែឮួរ (bungee jumping) ការឡើងភ្នំ ប្រណាំង ការជ្រមុជទឹក (Scuba diving) ការប្រណាំងក្នុងទម្រង់ណាមួយ។

**ការិយាល័យកណ្ដាល**


អគារ ជីអាយអេ ថៅអឺរ ជាន់ទី31 ផ្លូវសុភមង្គល ភូមិ14 សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា


**សាខាសៀមរាប**


អគារលេខ 29 និង 30
ផ្លូវហ្សាលដីហ្គោល សាលាកន្សែង សង្កាត់ស្វាយដង្គំ ទីរួមខេត្តសៀមរាប


**សាខាបាត់ដំបង**


ផ្ទះលេខ 2-6ផ្លូវលេខ 3 ភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង


**សាខាកំពង់ចាម**


ភូមិ 15 សង្កាត់កំពង់ចាម ខណ្ឌកំពង់ចាម ខេត្តកំពង់ចាម


**សាខាកំពត**


ផ្លូវលេខ 700 ភូមិ 1ឧសភា សង្កាត់កំពង់កណ្ដាល ក្រុងកំពត ខេត្តកំពត



086 999 242 | AIA.COM.KH | AIA CAMBODIA